


# កាសែតឡារ៉ែនពាណិជ្ជ ប្រចាំសប្តាហ៍




ឆ្នាំទី03 លេខទី99 ថ្ងៃចន្ទ ទី30 ខែតុលា - សៅរ៍ ទី04 ខែវិច្ឆិកា ឆ្នាំ2017
Year III, Issue 99. Mon 30 Oct - Sat 04 Nov 2017
LA REINE PEANICH WEEKLY NEWS
www.lareine.com.kh
la reine peanich
តម្លៃ 1,000៛

## សេដ្ឋកិច្ច និងពាណិជ្ជកម្ម

អ្នកធ្វើការឱ្យគេ...គួរចេញរកស៊ីខ្លួនឯងនៅពេលណា?



ទំព័រ 04

## អចលនទ្រព្យ និងសំណង់

ឡេង ណាវ៉ាត់ត្រា៖ បើមិនចេះត្រូវដើរជិតអ្នកចេះ យូរៗទៅយើងនឹងចេះដូចគេដែរ



ទំព័រ 09

## អប់រំ និងសង្គម

ហេតុអ្វីកូនក្មេងត្រូវអានសៀវភៅសម្រាប់កុមារ?



ទំព័រ 15

## អេឡិចត្រូនិក និងបច្ចេកវិទ្យា

Electrolux បោះជំហានកាន់តែរឹងមាំក្នុងទីផ្សារកម្ពុជា




ទំព័រ 18

## តើព្រះរាជពិធីបុណ្យអុំទូក ត្រូវបានប្រារព្ធឡើងក្នុងបំណងអ្វី?



អាននៅទំព័រ(3)

# CBC:របាយការណ៍ជាង13លានត្រូវបានធ្វើចាប់តាំងពីឆ្នាំ2012




អាននៅទំព័រ(3)

## ភាពជោគជ័យរបស់មហាសេដ្ឋីដែលចាប់ផ្តើមពីចំណុចសូន្យ



អាននៅទំព័រ(3)

## ការសិក្សានៅមហាវិទ្យាល័យត្រូវទាមទារការពិចារណាខ្ពស់ទើបជោគជ័យ

អាននៅទំព័រ(16)

អាជីវកម្មរីតតែងាយស្រួល ជាមួយអ៊ិនធឺណិតកាន់តែលឿន
Fiber Plus $660 ក្នុង១ឆ្នាំ
20Mbps (ពីមុន 15Mbps)
កាប្ញីអុបទិចផ្ទាល់ខ្លួន
ល្បឿនពេញផ្ទាល់ខ្លួន
សេវាបច្ចេកទេសនិងថែទាំ 24/7
អេស អាយ ណិត ក្រុមហ៊ុនជំនាញសេវាកម្មអ៊ិនធឺណិត DEDICATED.
Tel: 081 801 999 Email: sales@sinet.com.kh SINET KH
SINET

កាសែត ឡារ៉ែន ពាណិជ្ជ

**ចាងហ្វាង**
ហេង ប៊ុនណារ៉ែន

**ប្រធានគ្រប់គ្រងទូទៅ**
ហុង សុភ័ណ្ឌ

**និពន្ធនាយក**
ហ៊ឹន ពិសី

**អ្នកយកព័ត៌មាន**
វិន ឈុនហ៊ាត
អ៊ា សុវណ្ណារ៉ា
ហេង សុវណ្ណ
ប៉ែន ចាន់តារា

**ក្រាហ្វិកកុំព្យូទ័រ**
ខៀវ សុផល្លា
សោម ម៉ូលីវឌ្ឍនៈ
ស្រ៊ុន ពេជ្រ

**ផ្នែកព័ត៌មានវិទ្យា និងគេហទំព័រ**
កែវ វល័ក្ខ
តេង សុខឡៃ
ទី ចាន់ រ៉ាវី

**ផ្នែកលក់**
ព្រាប ផៃសូវាសនា
ហ្សូ ដាលី
គីម ណារិន
នេត ស្រីណែត
សាន្ត កេតតារារុធ

**ផ្នែកទីផ្សារ និងចែកចាយ**
ហេង ប៊ុនរី
ស្រី កុសល
អាង បូរី
អុំ ច័ន្ទសុភត្រា

អាសយដ្ឋាន: ផ្ទះលេខ 57,
មហាវិថីព្រះសីហនុ, ភ្នំពេញ
ទូរស័ព្ទ: 023 215 717 / 077 777 510
សារអេឡិចត្រូនិក: info@lareine.com.kh

សាកលវិទ្យាល័យន័រតុន
NORTON UNIVERSITY
បណ្តុះបណ្តាល អនាគតអ្នកដឹកនាំ
1996

# មាតិកា

## Business ពាណិជ្ជកម្ម
## អចលនទ្រព្យ Real Estate





ទំព័រ

03 តើព្រះរាជពិធីបុណ្យអុំទូក ត្រូវបានប្រារព្ធឡើងក្នុងបំណងអ្វី?
03 ភាពជោគជ័យរបស់មហាសេដ្ឋីដែលចាប់ផ្តើមពីចំណុចសូន្យ
03 ឡេង ណាវ៉ាត់ត្រា៖ បើមិនចេះត្រូវដើរជិតអ្នកចេះ យូរ ៗទៅយើងនឹងចេះដូចគេដែរ
04 CBC: របាយការណ៍ជាង13លានត្រូវបានធ្វើចាប់តាំងពីឆ្នាំ2012
04 អ្នកធ្វើការឱ្យគេ...គួរចេញរកស៊ីខ្លួនឯងនៅពេលណា?
05 អ្នកប្រកបអាជីវកម្មដំណាំកៅស៊ូចង់បានគោលនយោបាយកៅស៊ូ
05 ស្រូវក្រអូបចាប់ផ្តើមប្រមូលផល ជាមួយតម្លៃសមរម្យក្នុងឆ្នាំនេះ
06 ក្រុមហ៊ុនជប៉ុនជាង300 ធ្វើការលើជំនាញសំខាន់នឹងមកវិនិយោគនៅកម្ពុជា
08 CSS នឹងជួយឱ្យប្រតិបត្តិការអន្តរធនាគារតាមរយៈ ATM កាន់តែងាយស្រួល
09 ឱកាសមកដល់ហើយ! សម្រាប់អ្នកចង់បានរថយន្តតាក់ស៊ីធ្វើអាជីវកម្ម
10 DHA Siamwalla Ltd ប្រារព្ធពិធីជប់លៀងថ្លែងអំណរគុណដល់អតិថិជន
11 ខារ៉ាបាវ ស្វែងរកឃើញអ្នកឈ្នះរង្វាន់50លានរៀលលើកដំបូងនៅក្រុងបាវិត
11 ក្រុមហ៊ុនCBL រៀបចំពិធីជប់លៀងជូនដៃគូពាណិជ្ជកម្មអាពាហ៍ពិពាហ៍
11 EDM Cambodia រៀបចំកម្មវិធីតន្ត្រីដ៏ធំពុំធ្លាប់មាននៅកម្ពុជា

## Education អប់រំ
## បច្ចេកវិទ្យា Technology





ទំព័រ

15 ប្រជាជនខ្មែរគួរអភិវឌ្ឍខ្លួនឱ្យក្លាយជាប្រជាជនសកល
15 ហេតុអ្វីកូនក្មេងត្រូវអានសៀវភៅសម្រាប់កុមារ?
15 Honda Dream 125 ស៊េរីឆ្នាំ2018 ចេញលក់ហើយ
15 Electrolux បោះជំហានកាន់តែរឹងមាំក្នុងទីផ្សារកម្ពុជា
16 ការសិក្សានៅមហាវិទ្យាល័យត្រូវទាមទារការពិចារណាខ្ពស់ទើបជោគជ័យ
18 Samsung បោះទុន18ពាន់លានដុល្លារផលិតឈីបបន្ថែមទៀត



ក្រុមហ៊ុនជណ្តើរយន្តហ្វូជី ខេមបូឌា
FUJIHD 富士エレベーター Fuji Elevator
Tel:(855) 71-787 87 87
71-676 76 76
www.fujielevator.com.kh

# Business ពាណិជ្ជកម្ម
# អចលនទ្រព្យ Real Estate






# CBC: របាយការណ៍ជាង13លាន ត្រូវបានធ្វើចាប់តាំងពីឆ្នាំ2012




អានតទៅទំព័រ(4)



## ឡេង ណាវ៉ាត់ត្រា៖ បើមិនចេះត្រូវដើរជិតអ្នកចេះ យូរៗទៅយើងនឹងចេះដូចគេដែរ

និយាយពីតារាចម្រៀងឈ្មោះ លោក ឡេង ណាវ៉ាត់ត្រា ក្នុងវិស័យសិល្បៈគឺមានមហាជនជាច្រើនធ្លាប់បានស្គាល់រួចមកហើយក្នុងនាមលោកជាចាង-ហ្វាងផលិតកម្ម Galaxy។ ដោយឡែកក្នុងវិស័យអចលនទ្រព្យលោកហាក់មិនទាន់មានឈ្មោះល្បីល្បាញនោះទេ តែយ៉ាងណាក៏ដោយ សព្វថ្ងៃលោកគឺជាម្ចាស់គម្រោងសាងសង់ផ្ទះជាង200ល្វែងដែលស្ថិតនៅក្រោយផ្សារកាណាស៊ីធី។

ស្ថិតក្នុងកម្រិតជីវភាពបែបអ្នកជំនួញ វ័យមួយនឹងអាជីវកម្មដែលកំពុងបោះជោគជ័យមានមហាជនជាច្រើនបានគិតថា ប្រហែលជាមិនងាយស្រួលទេ ពុំនោះទេ ប៉ុន្តែប្រសិនបើដឹងពីប្រវត្តិពិត និងដំណើរជីវិតរបស់គាត់ក្នុងអាជីវកម្មនោះ យើងជឿថា និងមានមនុស្សជាច្រើន ...តទៅទំព័រ(៦)

## អ្នកធ្វើការឱ្យគេ...គួរចេញរកស៊ីខ្លួនឯងនៅពេលណា?



អានតទៅទំព័រ(4)



## តើព្រះរាជពិធីបុណ្យអុំទូក ត្រូវបានប្រារព្ធឡើងក្នុងបំណងអ្វី?

នៅថ្ងៃទី02 ដល់ថ្ងៃទី04 ខែវិច្ឆិកា ខាងមុខឆាប់ៗនេះប្រទេសកម្ពុជានឹងរៀបចំព្រះរាជពិធីបុណ្យអុំទូកបណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមដងទន្លេសាប នាមុខព្រះបរមរាជវាំង។ ដើម្បីដឹងថា តើព្រះរាជពិធីបុណ្យអុំទូកនេះធ្វើឡើងក្នុងគោលបំណងអ្វីនោះ កាសែត ឡារ៉ែន ពាណិជ្ជ បានដកស្រង់នូវឯកសារប្រវត្តិសាស្ត្រមួយចំនួន សម្រាប់ជូនមិត្តអ្នកអានដែលមានខ្លឹមសារដូចខាងក្រោម៖

ឯកសារប្រវត្តិសាស្ត្របានឲ្យ ...តទៅទំព័រ(៦)

## ភាពជោគជ័យរបស់មហាសេដ្ឋីដែលចាប់ផ្តើមពីចំណុចសូន្យ

ហេតុអ្វីបានជាមនុស្សមួយចំនួនអាចមានភាពជោគ-ជ័យធំធេងយ៉ាងនេះ? នោះដោយសារតែពួកគេមានជីវិតដែលល្អ មានឱកាស មានអ្នកនៅពីក្រោយគាំទ្រ បង្ហាញផ្លូវឱ្យយ៉ាងងាយស្រួល និងហេតុអ្វីអ្នកខ្លះទៀតទទួលបានភាពជោគជ័យមិនចាញ់គ្នានោះទេ តែមនុស្សទាំងនោះបែរជាត្រូវចាប់ផ្តើមជីវិតពីសូន្យ ឬគ្រួសារក្រីក្រ ទោះបីជាដូច្នេះ ហេតុអ្វីពួកគេអាចទទួលបានភាពជោគជ័យមិនចាញ់អ្នកដែលមានឱកាសល្អទាំងនោះ?

មហាសេដ្ឋីជាច្រើនបានបង្ហាញឱ្យឃើញថា ជីវិតមិនចាំបាច់ត្រូវតែមានមាសប្រាក់លុយកាក់មកតាំងពីកំណើតនោះឡើយ តែគេអាចសាងនិងរកវាមកបានដោយសមត្ថភាព។

មនុស្សជាច្រើនបានចាប់ផ្តើមពីកម្រិតមួយទៅមួយ តែពេលលោកខ្វះទៅអ្វីដែលពួកគេមានគឺគុណធម៌ និងវិជ្ជាជីវៈ ឈ្មោះល្បីល្បាញៗ ប្រៀបដូចជារូបរាងជីវិតរបស់ពួកគេ ពីមនុស្សពុំមានអ្វីសោះ ក្លាយទៅជាបុគ្គលដែលមានឈ្មោះល្បី...នោះដោយសារតែពួកគេហ៊ានក្នុងការប្រឈមនឹងភាពភ័យខ្លាច មិនញញើតនឹងឧបសគ្គដែលនៅខាងមុខ ជឿថាអ្វីដែលខ្លួនកំពុងធ្វើគឺត្រឹមត្រូវ ...តទៅទំព័រ(5)



អាចរកបានព័ត៌មានកាន់តែច្រើន
ក្នុង កាសែត ឡារ៉ែន ពាណិជ្ជ

THE MORE YOU CAN FIND IN
LA REINE PEANICH NEWS




lareine.peanich
www.lareine.com.kh
023 215 717 / 017 610 111


កាសែត
ឡាប៊ែន
ពាណិជ្ជ
អបអរសាទរ
ព្រះរាជពិធីបុណ្យអុំទូក អកអំបុក
បណ្តែតប្រទីប និងសំពះព្រះខែ
សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ស្ថាប័ន និងក្រុមហ៊ុន
ដែលតែងតែគាំទ្រលើសេវាកម្មផ្សព្វផ្សាយរបស់ ឡាប៊ែន
SOFITEL HOTELS & RESORTS
luxurySMILE
Coca-Cola
LOOKS
SCARLET FIBER MADE IN CAMBODIA
CARINO
Inthanou
Hong Soon
BIDC
ABC
ICHITAN
AXIS
HongLeong Bank
AEON
LG
FUJIHD
ORKIDE
LENGO
Monument Books
CAMBRIDGE
GREENPANEL
SINET
Canon
PICNIC
CAPITAL
CPL
truemoney
KFA
KANSAI PAINT Japan's No.1
Bodaiju Residences
SAMSUNG
Great Wall
TOWNCITY
LSi
CL REALTY
Hankook
The River
KHMER
គោរពជូនពី
កាសែត ឡាប៊ែន

# CSS នឹងជួយឱ្យប្រតិបត្តិការអន្តរធនាគារតាមរយៈ ATM កាន់តែងាយស្រួល




ធនាគារជាតិនៃកម្ពុជា (NBC) កាលពីពេលថ្មីៗនេះបានប្រកាសជាផ្លូវការនូវកិច្ចសហការជាមួយគ្រឹះស្ថានធនាគារអេស៊ីលីដា ធនាគារស្ថាបនា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាក់បញ្ញើប្រាសាក់ ក្នុងការដាក់ឱ្យដំណើរការបឋមនូវប្រព័ន្ធ Cambodian Shared Switch (CSS) ដែលជាប្រព័ន្ធរួមបញ្ចូលគ្នាមួយសម្រាប់សម្រួលដល់អតិថិជនក្នុងការប្រើប្រតិបត្តិការអន្តរធនាគារតាមរយៈបណ្តាញម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានជាសមាជិកបានប្រកបដោយភាពងាយស្រួល និងឆាប់រហ័ស។

ថ្លែងនៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ NBC បានឱ្យដឹងថា គោលបំណងនៃការដាក់ឱ្យដំណើរការជាបឋមនូវប្រព័ន្ធ CSS គឺដើម្បីធ្វើទំនើបកម្មប្រព័ន្ធទូទាត់ កាត់បន្ថយចរាចរសាច់ប្រាក់នៅលើទីផ្សារលើកកម្ពស់ប្រសិទ្ធភាពសេវាទូទាត់នៅកម្ពុជាឱ្យកាន់តែប្រសើរ និងជំរុញប្រតិបត្តិការអន្តរធនាគារឱ្យកាន់តែទូលំទូលាយ តាមរយៈការផ្តល់មធ្យោបាយថ្មីប្រតិបត្តិការបន្ថែមទៀតសម្រាប់អតិថិជន។

ជាមួយនឹងបណ្តាញ ATM ដ៏ទូលំទូលាយរបស់គ្រឹះស្ថានជាសមាជិក ប្រព័ន្ធនេះនឹងអនុញ្ញាតឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាធនាគារបាន ដែលនឹងអាចរួមចំណែកយ៉ាងសកម្មក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសេដ្ឋកិច្ច។

CSS ជាប្រព័ន្ធមួយដែលផ្តល់លទ្ធភាពដល់អតិថិជនរបស់គ្រឹះស្ថានជាសមាជិកក្នុងការធ្វើប្រតិបត្តិការទូទាត់ទំនិញ និងសេវាកម្មដកប្រាក់-ផ្ទេរប្រាក់អន្តរធនាគារ ពិនិត្យសមតុល្យគណនី និងប្រតិបត្តិការហិរញ្ញវត្ថុសាមញ្ញតាមម៉ាស៊ីន ATM ឬ POS របស់គ្រឹះស្ថានដែលជាសមាជិកប្រព័ន្ធ CSS។

គួរបញ្ជាក់ថា នាពេលជាប់ៗខាងមុខនេះ បន្ទាប់ពីដាក់ឱ្យដំណើរការបឋមបានជោគជ័យ អតិថិជនអាចប្រើម៉ាស៊ីន ATM ឬ POS បានកាន់តែទូលំទូលាយថែមទៀត ព្រោះក្រៅពីគ្រឹះស្ថានស្ថាបនិកទាំងបីនេះ នៅមានគ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាក់បញ្ញើផ្សេងទៀតបាន និងកំពុងមកដាក់ពាក្យស្នើសុំចូលរួមផងដែរ។

លោកបណ្ឌិត អ៊ុង ចាន់នី ប្រធានអគ្គនាយកប្រតិបត្តិនៃធនាគារអេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារឈានមុខគេនៅកម្ពុជា បានឱ្យដឹងថា ការអនុវត្តសេវាបែបនេះគឺជាការល្អ ព្រោះនៅកម្ពុជាមានធនាគារពាណិជ្ជ និងធនាគារឯកទេសសរុបចំនួន៦១ ដោយធនាគារនីមួយៗសុទ្ធតែមានទូ ATM រៀងៗខ្លួន ដូច្នេះការដាក់ឱ្យប្រើប្រាស់សេវា ATM រួមគ្នានេះគឺអាចធ្វើឱ្យធនាគារទាំងអស់តភ្ជាប់ជាមួយគ្នា ដោយអនុញ្ញាតឱ្យអតិថិជនអាចដកប្រាក់នៅធនាគារណាក៏បាន ខណៈដែលអេស៊ីលីដាមានទូ ATM សរុបជាង300គ្រឿងដាក់ពង្រាយនៅតាមទីប្រជុំជននានា។ លោកបណ្ឌិតបានបន្ថែមថា ការអនុវត្តបែបនេះគឺមានភាពងាយស្រួល ប៉ុន្តែអ្នកមានកាត ATM ដែលចង់ដកប្រាក់នៅធនាគារផ្សេង អតិថិជនត្រូវបង់កម្រៃសេវាកម្មពីការប្រើប្រាស់នោះ។

លោក អៀ សុជាតិ្ត នាយកអភិវឌ្ឍន៍អាជីវកម្ម និងជាប្រធាននាយកប្រតិបត្តិស្តីទីនៃការិយាល័យឥណទានកម្ពុជា (CBC) មានប្រសាសន៍ថា ការប្រកាសនេះធ្វើឡើងបន្ទាប់ពីមានកិច្ចប្រឹងប្រែងរវាងធនាគារនីមួយៗនៅក្នុងប្រទេសកម្ពុជា ហើយធនាគារនីមួយៗសុទ្ធតែបានបង្កើតនូវ ATM ដូចគ្នា គ្រាន់តែធនាគារខ្លះមានតិច និងធនាគារខ្លះមានច្រើនប៉ុណ្ណោះ។ លោកបន្តថា ប្រព័ន្ធថ្មីនេះនឹងផ្តល់ភាពងាយស្រួលដល់អតិថិជនដែលកាន់កាត ATM នៅធនាគារណាដែលមិនមានប្រាក់គ្រប់គ្រាន់ក្នុងការបង្កើតនូវ ATM ឱ្យបានច្រើន។

លោកលើកឡើងថា តាមពិតទៅប្រតិបត្តិការខាងលើ គេបានធ្វើរួចទៅហើយនៅប្រទេសជឿនលឿន ដោយនៅប្រទេសទាំងនោះមិនមានទូ ATM ដាក់តម្រៀបគ្នានៅកន្លែងតែមួយដូចនៅកម្ពុជានោះទេ ព្រោះខាងការដាក់ឱ្យអតិថិជនអាចដកប្រាក់គ្រប់ទូ ATM តែមួយរួមគ្នា។

គួរបញ្ជាក់ថា ដោយសារមន្ត្រីរាជការ កម្មកររោងចក្រ និងបុគ្គលិកក្រុមហ៊ុនឯកជនមួយចំនួនត្រូវបានដាក់ឱ្យបើកប្រាក់បៀវត្សតាមប្រព័ន្ធ ATM មកគេសង្កេតឃើញនៅពេលបើកប្រាក់ខែម្តងៗ ពួកគេតែងឈរតម្រង់ជួរគ្នាចាំបើកលុយ ប៉ុន្តែនៅពេលដាក់ឱ្យដំណើរការដកប្រាក់រួមគ្នានៅ ATM ផ្សេងគ្នាបានបែបនេះ នឹងធ្វើឱ្យការដំណើរការដកប្រាក់របស់ពួកគាត់ប្រព្រឹត្តទៅបានឆាប់រហ័ស មិនចំណាយពេលរង់ចាំយូរដូចមុនទៀតទេ។



# AuntieAnne’sបើកដំណើរការហាងទី1របស់ខ្លួននៅកម្ពុជា





នៅពេលនេះប្រជាជនខ្មែរគឺជាអ្នកភ្លក្សរស-ជាតិដ៏ឈ្ងុយឆ្ងាញ់ និងថ្មីនៃនំប្រេតហ្សែលរបស់ AuntieAnne'sពីប្រទេសអាមេរិកដែលភាគច្រើនក្នុងតំបន់ផ្សារទំនើប ខណៈហាងនំ AuntieAnne's បានត្រូវបានបើកដំណើរការនៅក្នុងរាជធានីភ្នំពេញ។

Auntie Anne's Pretzels គឺជាស្លាកយីហោនំប្រេតហ្សែលដ៏ធំបំផុតលើពិភពលោក ដែលផលិតដោយដៃ និងបានសាងភាពល្បីល្បាញតាមរយៈការលាយម្សៅម្ដងៗ និងដុតនំប្រេតហ្សែលដោយប្រណីត ដោយភាពស្រស់ៗ។ AuntieAnne's នឹងផ្ដល់ជូនជម្រើសនំប្រេតហ្សែលច្រើនប្រភេទ រួមមានរសជាតិដ៏ឈ្ងុយឆ្ងាញ់ផ្សេងៗគ្នា ដល់ប្រជាជនខ្មែរដែលរួម-មានរសជាតិដើម អាល់ម៉ុន ស៊ីនណាម៉ុន-ស៊ុយក្រ ពេប៉េរ៉ូនី និងនំប្រេតហ្សែលហតដក ហើយក្នុងនោះអតិថិជនក៏អាចធ្វើការជ្រើសរើសទឹកជ្រលក់ដែលរៀបចំយ៉ាងពិសេស ដើម្បីបន្ថែមរសជាតិម្យ៉ាងទៀតទៅលើរសជាតិនំប្រេតហ្សែល មានន័យថាប្រជាជនខ្មែរនឹងមានជម្រើសរសជាតិអាហារសម្រន់កាន់តែសម្បូរបែប។

ជាមួយជម្រើសអាហារ និងអាហារសម្រន់ជាច្រើនប្រភេទ Auntie Anne's គឺជាគោលដៅដ៏ពេញនិយមដែលបម្រើជូនអ្នកហូបអាហាររហ័សទាន់ចិត្តដែលលោកអ្នកអាចស្វែងរកបាននៅផ្សារទំនើប ហាងទំនិញ អាកាសយានដ្ឋាន ស្ថានីយរថភ្លើង មណ្ឌលកម្សាន្ត មហាវិទ្យាល័យ សាកលវិទ្យាល័យ Walmart និងតំបន់កម្សាន្តផ្សេងៗនៅតាមបណ្ដាប្រទេសជាច្រើន។

ហាងនំAuntieAnne'sកំពុងលក់នំប្រេតហ្សែលដែលធ្វើថ្មីៗក្តៅៗនៅជាង 1,600កន្លែងនៅក្នុងរដ្ឋចំនួន 48នៅសហរដ្ឋអាមេរិក និង30កន្លែងទៀតនៅក្នុងប្រទេសនានាជុំវិញពិភពលោក។ រាល់នំប្រេតហ្សែលទាំងអស់ត្រូវបានធានាលើគុណភាព "ពិល្អឥតខ្ចោះ"មានន័យថាប្រសិនបើអតិថិជនមិនពេញចិត្តជាមួយនំប្រេតហ្សែលដែលខ្លួនបានទទួលនោះ Auntie Anne's នឹងប្តូរជូននូវនំប្រេតហ្សែលថ្មីដែលអតិថិជនពេញចិត្តភ្លាមៗតែម្តង។

រូបមន្តរបស់ "Auntie" ដែលលោកស្រី Anne Beiler និងស្វាមីរបស់គាត់គឺលោក Jonas បានរកឃើញ នៅតែត្រូវបានបន្តប្រើជាគ្រឿងផ្សំរហូតដល់ពេលបច្ចុប្បន្ន។ Auntie Anne's បានទទួលការពេញនិយម និងល្បីល្បាញជានិមិត្តសញ្ញានៃនំប្រេតហ្សែលថ្មីៗ ក្តៅហ៊ុយៗ និងជានំដែលធ្វើដោយដៃផ្ទាល់តែម្តង។

សូមអញ្ជើញមកកាន់សាខាទីមួយរបស់ហាងនំប្រេតហ្សែល Auntie Anne's ក្នុងប្រទេសកម្ពុជា ដើម្បីភ្លក្សរសជាតិនំប្រេតហ្សែល និងអាហារសម្រន់ផ្សេងៗទៀតប្រកបដោយភាពឈ្ងុយឆ្ងាញ់ នៅផ្សារទំនើបសុរិយា សេនធើ៕

# DHA Siamwalla Ltd ប្រារព្ធពិធីជប់លៀងថ្លែងអំណរគុណដល់អតិថិជន

DHAS គឺជាក្រុមហ៊ុនដំបូងគេនៅអាស៊ីដែលមានផលិតគ្រឿងលោហៈផ្ទាល់ខ្លួន និងម៉ាស៊ីនផលិតហ្វីលប្លាស្ទិក ( Plastic film extrusion ) សម្រាប់ផលិតវត្ថុជាខ្សែចង្វាក់ផលិតកម្មទាំងមូលទៅដល់ការផលិតគ្រាប់ផលិតផលពីប៉ូលី Polypropylene ដែលនាំមកនូវការកាត់បន្ថយលើការចំណាយ និងបង្កើនសុវត្ថិភាពដល់សុខភាពអតិថិជន ព្រមទាំងចូលរួមថែរក្សាបរិស្ថានផងដែរ។

ផលិតផលរបស់ក្រុមហ៊ុន DHAS បាននិងកំពុងលក់នៅទូទាំងប្រទេសកម្ពុជាអស់រយៈពេលជាងមួយទសវត្សមកហើយ។ ក្នុងពិធីជប់លៀងថ្លែង-អំណរគុណអតិថិជនដែលរៀបចំឡើងនៅសណ្ឋា-គារសុហ្វីតែល ភ្នំពេញ កាលពីពេលថ្មីៗនេះ លោក Suharit Siamwalla នាយកគ្រប់គ្រងក្រុម-ហ៊ុន DHAS បានប្រកាសថា ប្រទេសកម្ពុជា គឺជាទីផ្សារពិសេស ហើយយើងមានគម្រោងណែនាំនូវផលិតផលថ្មីៗ និងមានគុណភាពខ្ពស់បន្ថែមទៀតនៅទីនេះ ស្របពេលដែលប្រជាជនខ្មែរបានទទួលស្គាល់ និងពេញចិត្តជាមួយនឹងគុណភាពដ៏ល្អរបស់ផលិតផលយើងរួចជាស្រេចហើយ។

នៅក្នុងពិធីជប់លៀងថ្លែងអំណរគុណអតិថិជននេះមានក្រុមអ្នកចែកចាយ និងលក់រាយចូលរួមប្រមាណជាង250នាក់ ជាពិសេសមានវត្តមានរបស់លោក ស៊ុន ប៊ុនឡូ នាយកគ្រប់គ្រងនៃក្រុម-ហ៊ុន ទី ស៊ាង អ៊ីមផត អិចផត ដែលជាក្រុមហ៊ុនចែកចាយតែមួយគត់ប្រចាំនៅក្នុងប្រទេសកម្ពុជារបស់ DHAS។

លោក Suharit Siamwalla បានថ្លែងថា៖ "ដើម្បីធ្វើដំណើរឆ្ពោះទៅមុខ DHAS មិនត្រឹមតែណែនាំផលិតផលថ្មីៗប៉ុណ្ណោះទេ តែថែមទាំងពង្រឹងទំនាក់ទំនងរវាងអតិថិជនក្នុងស្រុកឱ្យកាន់តែប្រសើរ។ ជាមួយគ្នានេះ DHAS សូមជម្រាបជូនដល់អតិថិជនឱ្យដឹងពីអ្វីដែល DHASកំពុងធ្វើ ហើយសំខាន់បំផុតគឺដើម្បីចាប់ផ្តើមធ្វើដំណើររួមគ្នា និងពង្រីកវិសាលភាពនៃទំនុកចិត្តរបស់អតិថិជនខ្មែរក្នុងការជ្រើសរើសផលិតផលដែលមានគុណភាព"។

គួរបញ្ជាក់ថា DHASiamwalla Ltd., ជាក្រុមហ៊ុនផលិតសម្ភារសិក្សា និងសម្ភារការិយាល័យ ដែលត្រូវបានបង្កើតឡើងនៅប្រទេសថៃ តាំងពីឆ្នាំ 1907 មកម្ល៉េះ។ ក្រុមហ៊ុននេះមានផលិត និងចែកចាយសម្ភារការិយាល័យដែលមានគុណ-ភាពខ្ពស់ជាច្រើនប្រភេទរួមមានទាំងស៊ីម ក្រដាស និងប្រអប់ទុកឯកសារហ្វូលឌ័រ ( Folder ) សៀវភៅសរសេរ និងផលិតផលគុណភាពផ្សេងៗ ក្រោមស្លាកសញ្ញាច្រើនរាប់ប្រភេទ ដែលស្លាកសញ្ញានីមួយៗមានកេរ្តិ៍ឈ្មោះល្បីខាងគុណភាព និងទទួលបានការពេញនិយមក្នុងការប្រើប្រាស់យ៉ាងច្រើន៕







# ខាំបាវ ស្វែងរកឃើញអ្នកឈ្នះរង្វាន់50លានរៀលលើកដំបូងនៅក្រុងបាវិត



ជាមួយនឹងកម្មវិធីដ៏អស្ចារ្យដើម្បីលើកទឹកចិត្តដល់អតិថិជនរបស់ខ្លួន ក្រុមហ៊ុនភេសជ្ជៈប៉ុកម៉ាង ខាំបាវ កាលពីសប្តាហ៍កន្លងមកបានរកឃើញអតិថិជនមានសំណាងឈ្នះរង្វាន់ធំចំនួនទឹកប្រាក់50លានរៀលដែលជាប្រជាពលរដ្ឋរស់នៅក្រុងបាវិត នាខេត្តស្វាយរៀង។

ស្ថិតក្នុងសភាពត្រេកអរ លាយឡំនឹងទឹកភ្នែក ដែលបង្ហាញពីក្តីរំភើបជាមួយនឹងមហាសំណាងរបស់ខ្លួនដែលគ្មាននរណាស្មានថាប្រាក់លានលើកដំបូងរបស់ភេសជ្ជៈប៉ុកម៉ាង ខាំបាវ លោក គុណ ម៉េង អាយុ១៧ឆ្នាំ បាននិយាយថា លោកមានស្រុកកំណើតនៅខេត្តកំពង់ចាម ប៉ុន្តែដោយសារជីវភាពគ្រួសារមានភាពលំបាក លោក និងភរិយាក៏បានមកចាប់ផ្តើមការងាររបស់គាត់នៅភូមិ ស៊ីណូ ក្នុងក្រុងបាវិត ខេត្តស្វាយរៀង ដោយស្នាក់នៅក្នុងបន្ទប់ជួលតូចមួយ។

លោកអះអាងថា ស្ទើរតែរាល់ថ្ងៃនៅពេលចេញពីធ្វើការនឿយហត់អស់កម្លាំង លោកតែងញ៉ាំភេសជ្ជៈខាំបាវមកទទួលទានជាប្រចាំ។ ដោយឡែកនៅពេលបើកគ្រប់ក៏លោកមិនបានគិតថាប្រាក់រង្វាន់ធំមកដល់ ព្រោះក្រៅពីធ្វើឲ្យមានកម្លាំង រីឯមុខងារឲ្យស្រស់ស្រាយក្នុងពេលធ្វើការងារទៀតនោះ អ្វីដែលធ្វើឲ្យលោកភ្ញាក់ផ្អើលស្ទើរមិនគួរឲ្យជឿនោះ គឺកាលពីពេលថ្មីៗនេះនៅពេលដែលលោកញ៉ាំខាំបាវមកទទួលទានដូចសព្វដង ស្រាប់តែបានឃើញរង្វាន់50លានរៀលនៅនឹងក្រវិលកំប៉ុង ហេតុនោះគាត់គិតថាជាការយល់សប្តិ។

អតិថិជនដែលឈ្នះរង្វាន់ធំប្រាក់លានលើកដំបូងរបស់ខាំបាវរូបនេះបានបញ្ជាក់ថា៖ "មុនដំបូងខ្ញុំដូចជាមិនជឿខ្លួនឯងនោះទេ ហើយក៏បានហៅអ្នករស់នៅជិតខាងឲ្យជួយមើលព្រោះខ្លាចមិនពិត។ បន្ទាប់ពីនេះខ្ញុំបានទូរស័ព្ទទៅកាន់លេខក្រុមហ៊ុនដែលមាននៅនឹងក្រវិលកំប៉ុង ដោយក្រុមហ៊ុនប្រាប់ថា ពិតជារង្វាន់ពិត។ ខ្ញុំអរស្ទើរតែលោតផុតដី ព្រោះមិនធ្លាប់គិតថាខ្លួនមានសំណាងបានទាំងប្រាក់ច្រើនសន្ធឹកសន្ធាប់បែបនេះទេ។ ខ្ញុំនឹងយកប្រាក់ទាំងនេះទៅធ្វើជាដើមទុនប្រកបអាជីវកម្មដើម្បីប្រែប្រួលជីវភាពគ្រួសាររបស់ខ្ញុំ។ ខាំបាវ ពិតជាបានធ្វើឲ្យជីវភាពគ្រួសាររបស់ខ្ញុំមានភាពល្អប្រសើរពិតមែន"។

សូមបញ្ជាក់ថា ក្រុមហ៊ុនភេសជ្ជៈប៉ុកម៉ាងខាំបាវ នៅតែបន្តការចែកជូន និងផ្តល់សំណាងដល់អតិថិជនរបស់ខ្លួនជានិច្ច ដែលក្នុងនោះរួមមានទឹកប្រាក់50លានរៀល ចំនួន40រង្វាន់ ម៉ូតូ HONDA Dream 125 ស៊េរីឆ្នាំ 2017 ចំនួន40រង្វាន់ ទូរស័ព្ទដៃ iPhone7 ចំនួន40រង្វាន់ រួមជាមួយការផ្តល់ជូនរង្វាន់ភេសជ្ជៈប៉ុកម៉ាងខាំបាវ1កំប៉ុងរាប់លានរង្វាន់ និងគ្មានការកំណត់កាលបរិច្ឆេទ។ អ្នកទាំងអស់គ្នាមានសំណាងបានឈ្នះរង្វាន់ធំ អ្នកលក់ម្នាក់ៗត្រូវរង្វាន់ពិតនឹងមានសំណាងបានទទួលរង្វាន់5លានរៀលដោយឡែកសម្រាប់អ្នកតាំងលក់ស្ពាតផងដែរ ពេលក្រុមការងារចុះទៅពិនិត្យនិងទទួលបានប្រាក់រង្វាន់ចំនួន50ម៉ឺនរៀល។ សូមចំណាំ សម្រាប់រង្វាន់ពិតប្រាកដ គឺមានតែនៅសម្បកកំប៉ុង ដែលមានអក្សរខ្មែរជាសញ្ញាសម្គាល់តែប៉ុណ្ណោះ៕

# ក្រុមហ៊ុនCBL រៀបចំពិធីជប់លៀង ជូនដៃគូពាណិជ្ជកម្មអាពាហ៍ពិពាហ៍







ក្រុមហ៊ុនផលិតស្រាបៀរកម្ពុជា ( CBL ) កាលពីសប្តាហ៍កន្លងមកបានរៀបចំកម្មវិធីធំមួយនៅសណ្ឋាគារសុខា ភ្នំពេញ ដើម្បីប្រកាសបើកទំព័រ Facebook Fan Page ( Party and Celebration ) របស់ក្រុមហ៊ុន រួមនឹងកម្មវិធីប្រូម៉ូសិនថ្មីសម្រាប់រដូវកាលអាពាហ៍ពិពាហ៍ ឆ្នាំ2017-2018។

កម្មវិធីពិសេសនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងចំណងទំនាក់ទំនងជាមួយដៃគូពាណិជ្ជកម្មអាពាហ៍ពិពាហ៍របស់ក្រុមហ៊ុន CBL និងអតិថិជនទាំងអស់ដែលបានជាវស្រាបៀរគ្រប់ម៉ាកសញ្ញារបស់ក្រុមហ៊ុន CBL រួមមានស្រាបៀរ Heineken ABC Tiger Anchor Gold Crown និង Gold Crown Stout សម្រាប់រៀបចំបុណ្យភ្ញៀវក្នុងពិធីមង្គលការនៅទូទាំងប្រទេសកម្ពុជា។

អ្នកដែលអញ្ជើញចូលរួមក្នុងកម្មវិធីនេះរួមមាន ម្ចាស់ហាងលក់ភេសជ្ជៈ អ្នកបម្រើម្ហូបការពារ ចុងភៅ មេការ និងភ្ញៀវកិត្តិយសជាច្រើនទៀត។ ចំពោះម្ចាស់កម្មវិធីអាពាហ៍ពិពាហ៍ ដែលបានជាវស្រាបៀរម៉ាកសញ្ញាណាមួយរបស់ក្រុមហ៊ុន CBL ដូចជា Heineken ABC Tiger Anchor Gold Crown និង Gold Crown Stout នឹងទទួលបានកម្មវិធីប្រូម៉ូសិនពិសេសៗនារដូវកាលអាពាហ៍ពិពាហ៍ថ្មីនេះ ខណៈអ្នកដែលនាំពេលការក៏នឹងទទួលបានកញ្ចប់រង្វាន់លើកទឹកចិត្តជាច្រើនពីក្រុមហ៊ុន CBL ផងដែរ។

បន្ទាប់ពីប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ ក្រុមហ៊ុន CBL បានរៀបចំបន្តព្រឹត្តិការណ៍កម្មវិធីនេះនៅខេត្តសៀមរាបនិងខេត្តព្រះសីហនុ ថ្ងៃទី23 ខែតុលា ឆ្នាំ2017 នៅសណ្ឋាគារសុខា ខេត្តកំពង់ចាម ថ្ងៃទី26 ខែតុលា ឆ្នាំ2017 នៅសណ្ឋាគារ អ៊ិលប៊ីអ៊ិន ភាសាន និងខេត្តសៀមរាប ថ្ងៃទី31 ខែតុលា ឆ្នាំ2017 នៅសណ្ឋាគារសុខា៕

# EDM Cambodia រៀបចំកម្មវិធីតន្ត្រីដ៏ធំពុំធ្លាប់មាននៅកម្ពុជា



ក្រុម EDM Cambodia បានសហការជាមួយក្រុមហ៊ុនស្រាបៀរ Heneken រៀបចំព្រឹត្តិការណ៍រាំរែកដ៏អស្ចារ្យមួយមានឈ្មោះថា "Afterlife Asylum" ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារកោះពេជ្រ យ៉ាណា កាលពីថ្ងៃសៅរ៍ ទី28 ខែតុលា ចាប់ពីម៉ោង 4ល្ងាច រហូតដល់ម៉ោង11យប់។

"Afterlife: Asylum" គឺជាកម្មវិធីរាំរែកដ៏ធំបំផុតដែលមិនធ្លាប់មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កម្មវិធីនេះបាននាំមកនូវអ្នកចូលរួមរាប់ពាន់នាក់ រាំរែកពីរសេសពីសាលតន្ត្រីអេឡិចត្រូនិក ស្ទូឌីយ៉ូប្រកបដោយគុណភាពខ្ពស់ និងផលិតកម្មលំដាប់ពិភពលោក ដែលមានឈ្មោះថា Three 6 ក្រុមចម្រៀងការសម្តែងពិសេសៗដ៏អស្ចារ្យជាច្រើនទៀត។

សមាជិកក្រុម EDM Cambodia បានប្រាប់ឲ្យដឹងថា តារាល្បីប្រចាំកម្មវិធីនេះ គឺ DJ មកពីប្រទេសហូឡង់ ដែលមានឈ្មោះថា Debris ។ នៅក្នុងស្នាដៃតន្ត្រីរបស់គាត់ Debris បានប្រើប្រាស់បញ្ចូលគ្នារវាងប្រភេទតន្ត្រី EDM ទំនើបស៊េរីង និងសំនៀងដើមមកពីចក្រភពអង់គ្លេស ដែលធ្លាប់ទទួលបានជោគជ័យជាច្រើនលើសពីមកហើយ។ មានបទចម្រៀង DJ. Mag ដែលជា DJ ឈ្នះ Top 3 នៅក្នុងតារាងចំណាត់ថ្នាក់ប្រចាំក្រុម EDM រួមជាមួយក្រុម "Lucky Strike"។

នៅក្នុងការសម្តែងរួមគ្នាលើឆាកដែលមាន DJ ក្នុងតំបន់ Botoosh មកពីប្រទេសថៃ ក៏ដូចជា DJ ល្បីៗជាច្រើនប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការសម្តែងពិសេសៗពីក្រុម Univeso Robot Team of Pyrotechnics ជាមួយនឹងបច្ចេកវិទ្យា LED ដ៏អស្ចារ្យ បានធ្វើឲ្យទស្សនិកជនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។

ព្រឹត្តិការណ៍ពិសេសនេះបានក្លាយជាបទពិសោធន៍អស្ចារ្យមួយក្នុងការកម្សាន្តសប្បាយរីករាយជាមួយនឹងកម្មវិធីជប់លៀង និងតន្ត្រី៕


Inthanou
Quality, Reliable, Comfortable
AMERICANSTAR®
អបអរសាទរព្រះរាជពិធីបុណ្យ
អុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក
លក់បញ្ចុះតម្លៃពិសេស
20%
ចាប់ពីពេលនេះ
រហូតដល់ថ្ងៃទី 30 វិច្ឆិកា 2017
ឯកទេសពូកតែ
1 គត់នៅកម្ពុជា
ផ្ទះលេខ៤២០-៤២២ ផ្លូវលេខ៣១០ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: 015 789 002 / 089 789 002




# Education អប់រំ
# បច្ចេកវិទ្យា Technology






## ប្រជាជនខ្មែរគួរអភិវឌ្ឍខ្លួនឱ្យក្លាយជាប្រជាជនសកល



ការអភិវឌ្ឍធនធានមនុស្សជាផ្នែកដ៏សំខាន់ដែលមិនអាចខ្វះបានសម្រាប់ប្រទេសទាំងអស់នៅលើពិភពលោក ព្រោះមនុស្សជាធនធានដែលមិនចេះរីងស្ងួតសម្រាប់សង្គម ហើយអាចជំរុញឱ្យសង្គមមានការអភិវឌ្ឍកាន់តែខ្លាំង និងឈានដល់ការប្រកួតប្រជែងជាលក្ខណៈអន្តរជាតិថែមទៀតផង។

កត្តាដែលជំរុញឱ្យធនធានមនុស្សក្នុងប្រទេសមួយខ្លាំង គឺកើតចេញពីស្ថាប័នរដ្ឋ និងឯកជន រួមទាំងប្រជាពលរដ្ឋម្នាក់ៗដែលមានឆន្ទៈក្នុងការអភិវឌ្ឍខ្លួនឯងឱ្យក្លាយជាមនុស្សខ្លាំងសម្រាប់ចូលរួមអភិវឌ្ឍស្ថាប័នដែលខ្លួនកំពុងធ្វើការ និងសង្គមជាតិទាំងមូល។

លោក ស៊ាង សុបញ្ញា នាយកវិទ្យាស្ថានកម្ពុជា-អាស៊ាន បានលើកឡើងថា ប្រជាជនកម្ពុជាពិសេសយុវជនដែលកំពុងសិក្សានៅតាមសាកលវិទ្យាល័យ គួរតែខិតខំអភិវឌ្ឍខ្លួនឱ្យក្លាយជាប្រជាជនដែលមានសមត្ថភាពកម្រិតអន្តរជាតិ (Global Citizen)។ បុគ្គលដែលមាន ...តទៅទំព័រ(16)

## ហេតុអ្វីកូនក្មេងត្រូវអានសៀវភៅសម្រាប់កុមារ?



ក្មេងៗជាអនាគតធនធានមនុស្សដ៏សំខាន់សម្រាប់សង្គម ហើយនៅពេលដែលក្មេងតូចៗត្រូវបានអភិវឌ្ឍល្អនោះ ពួកគេនឹងក្លាយជាមនុស្សដែលពោរពេញទៅដោយសមត្ថភាព ឬក៏អាចសម្រេចបានក្តីស្រមៃរបស់ឪពុកម្តាយ និងក្រុមគ្រួសារផងដែរ។

ដើម្បីអភិវឌ្ឍសមត្ថភាពក្មេង ការអាន គឺជាគន្លឹះដ៏សំខាន់ដែលមិនអាចខ្វះបាន ព្រោះថានៅពេលពួកគេចាប់ផ្តើមចេះអាន ...តទៅទំព័រ(17)

## Honda Dream 125 ស៊េរីឆ្នាំ2018 ចេញលក់ហើយ

ជាមួយនឹងការទន្ទឹងរង់ចាំយ៉ាងអន្ទះសាពីសំណាក់អ្នកគាំទ្រ និងអ្នកប្រើប្រាស់ កាលពីរាត្រីថ្ងៃទី27 ខែតុលា កន្លងទៅម៉ូតូម៉ាកហុងដាឌ្រីម 125 ស៊េរីថ្មី ឆ្នាំ2018 ដ៏ប្រណីតបានបង្ហាញខ្លួននៅ Koh Pich ក្នុងសាល City Hall។ ដោយកម្មវិធីទាំងមូលមានដូចជា សកម្មភាពសម្ពោធម៉ូតូម៉ាកហុងដាឌ្រីម 125 ស៊េរីថ្មី ការសម្តែងពិសេស និងការទទួលទានអាហារពេលល្ងាចជុំគ្នា។

លោក Ben Kiasrithanakorn អគ្គនាយកក្រុមហ៊ុន N.C.X. Company Limited បានឱ្យដឹងថា កម្មវិធីនេះរៀបចំឡើងដោយមានការចូលរួមពីភ្នាក់ងារចែកចាយម៉ូតូម៉ាកហុងដា និងដៃគូពាណិជ្ជកម្មទាំងអស់របស់ក្រុមហ៊ុន។ The Golden Masterpiece បានអ្នះ ...តទៅទំព័រ(17)

## ការសិក្សានៅមហាវិទ្យាល័យត្រូវទាមទារការពិចារណាខ្ពស់ទើបជោគជ័យ

អានទៅទំព័រ(16)

## Electrolux បោះជំហានកាន់តែរឹងមាំក្នុងទីផ្សារកម្ពុជា




Electrolux ដែលជាក្រុមហ៊ុនល្បីល្បាញឈានមុខគេក្នុងពិភពលោកសម្រាប់សម្ភារៈគ្រួសារ និងគ្រឿងអេឡិចត្រូនិកដ៏ល្អឯកមកពីអឺរ៉ុបបានបើកសម្ពោធផលិតផលរបស់ខ្លួនជាផ្លូវការហើយក្នុងប្រទេសកម្ពុជាកាលពីពេលថ្មីៗនេះ នេះជាមួយនឹងគោលបំណងដ៏សំខាន់បំផុតគឺ “Happiness Together”។

លើសពីនេះក្រុមហ៊ុនក៏បានប្រកាសថានឹងធ្វើការអភិវឌ្ឍ ព្រមទាំងពង្រីកយុទ្ធសាស្ត្រទីផ្សារក្នុងប្រទេសកម្ពុជា ឱ្យបានកាន់តែ ...តទៅទំព័រ(16)



# ប្រជាជនខ្មែរគួរអភិវឌ្ឍខ្លួនឱ្យក្លាយជា...




តពីទំព័រ 15 ;... សមត្ថភាពខ្លាំងជាសកលបែបនេះ គឺជាបុគ្គលដែលអាចធ្វើការងារបាននៅគ្រប់ប្រទេសទាំងអស់លើពិភពលោក ឬមានចំណេះជំនាញគ្រប់គ្រាន់ក្នុងការផ្ដើមចំណែកទីផ្សារការងារសំខាន់ៗនៅបរទេស។

លោក ស៊ាង សុបញ្ញា បាននិយាយថា៖ "ដើម្បីក្លាយខ្លួនជាបុគ្គលដែលមានការងារធ្វើ និងកម្រិតសមត្ថភាពជាអន្តរជាតិ ពួកគេត្រូវតែមានជំនាញធំៗ 2 ជាគោល គឺជំនាញភាសា និងជំនាញបច្ចេកទេសឱ្យបានច្បាស់លាស់។ ភាពច្បាស់នៃជំនាញភាសានេះ គឺមិនមែនគ្រាន់តែអានបាន ឬនិយាយស្ទាក់ស្ទើរបានបែបធម្មតា នោះទេ គឺចាំបាច់ត្រូវចេះច្បាស់លាស់អាចបកប្រែបាន អធិប្បាយ ឬសរសេរលិខិតផ្លូវការបានដោយល្អ"។

សាស្ត្រាចារ្យរូបនេះ បានលើកឡើងថា នៅពេលដែលយើងអាចយល់ច្បាស់ពីភាសាហើយ យើងនឹងមានឧបករណ៍សម្រាប់ការស្រាវជ្រាវជាសកល ដើម្បីឈានទៅដល់ភាពជាអ្នកជំនាញដែលមានគុណភាពក្នុងការគិត និងអនុវត្តខ្ពស់។ ចំពោះជំនាញបច្ចេកទេសវិញ ក៏ជាជំនាញចាំបាច់មួយដែរ ព្រោះបច្ចុប្បន្ននេះ អាស៊ានបានបើកចំហឱ្យអាជីពមួយចំនួនដើម្បីឱ្យប្រជាជននៅក្នុងប្រទេសដែលជាសមាជិកទាំងអស់មានឱកាសស្វែងរកការងារធ្វើនៅក្នុងប្រទេសទាំង១០នេះ។ ប្រសិនបើយើងមានជំនាញច្បាស់លាស់ ហើយចេះប្រើភាសាច្បាស់លាស់ យើងនឹងអាចឆ្លងចូលទៅធ្វើការងារនៅបរទេសបាន និងមិនមែនប្រកួតប្រជែងតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ។

លោក គឹម អៀង នាយកវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ បានលើកឡើងថា មេដឹកនាំល្អគឺជាមេដឹកនាំដែលចេះនាំប្រជាជនឱ្យក្លាយជាប្រជាជនសកល ហើយប្រជាជនខ្លួនឯងក៏ត្រូវតែមានឆន្ទៈក្នុងការអភិវឌ្ឍខ្លួនដោយផ្ដោតសំខាន់លើអត្តភាពសំខាន់ៗចំនួន៣ គឺមនុស្ស បរិស្ថាន និងចំណូល។ ការលើកឡើងពីកត្តាមនុស្សនេះ គឺចង់សំដៅលើការអប់រំ និងការលើកតម្លៃមនុស្សគ្រប់រូបដោយការផ្ដល់ឱកាសចែករំលែក និងជួយគ្នាទៅវិញទៅមកប្រកបដោយភាពស្មោះត្រង់។

ចំណុចសំខាន់មួយផ្សេងទៀត គឺធម្មជាតិ ឬបរិស្ថាន មានន័យថា មនុស្សត្រូវតែគិតឱ្យបានល្អិតល្អន់ពីសកម្មភាពរបស់ខ្លួនប្រចាំថ្ងៃចំពោះពិភពលោក និងមិនចូលរួមការបំផ្លាញពិភពលោកដោយប្រយោល។

លោក គឹម អៀង បាននិយាយថា៖ "ការគិតពីផលប្រយោជន៍គិតគូរពីពិភពលោក គឺអាចធ្វើឱ្យយើងរស់នៅក្នុងភាពសុខដុមទាំងអស់គ្នា ហើយនៅពេលដែលមនុស្សធ្វើខ្លួនដោយមានភាពហ្មត់ចត់ ហើយចូលរួមថែរក្សាពិភពលោកតាមរយៈការសន្សំសំចៃថាមពលអគ្គិសនី ការគ្រប់គ្រងសំរាមបានល្អ និងការដាំដើមឈើជាដើម អាចធ្វើឱ្យយើងរស់នៅក្នុងភាពស្ងប់សុខ"។

លោក គឹម អៀង បានបញ្ជាក់ថា រឿងចំណូលជារឿងចុងក្រោយបំផុតបន្ទាប់ពីរឿងមនុស្ស និងបរិស្ថាន តែទោះជាយ៉ាងណាក៏មនុស្សត្រូវការការរកចំណូលដែលល្មមត្រឹមត្រូវ និងតោងពឹងផ្អែកលើគោលការណ៍ស្មោះត្រង់ដែលមិនប៉ះពាល់អ្នកដទៃ ហើយរស់នៅជាមួយគ្នាប្រកបដោយភាពថ្លៃថ្នូរ។




# ការសិក្សានៅមហាវិទ្យាល័យត្រូវទាមទារការពិចារណាខ្ពស់ទើបជោគជ័យ



ការសិក្សានៅមហាវិទ្យាល័យ អាចនិយាយថាជាជំហានថ្មីមួយឆ្ពោះទៅកាន់ឧត្តមភាព និងភាពជាអ្នកដែលមានជំនាញច្បាស់លាស់ទៅថ្ងៃអនាគត។ សិស្សដែលទើបបានបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ចាំបាច់ត្រូវយកចិត្តទុកដាក់ឱ្យបានច្បាស់លាស់ទៅលើផ្លូវឆ្ពោះទៅកាន់ភាពជោគជ័យ តាមរយៈការ "សម្រេចចិត្តត្រូវ ជ្រើសរើសត្រូវ និងសិក្សាត្រូវ"។

ឯកឧត្តម អ៊ាង សុផល្លែត អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងនៅក្នុងកម្មវិធីពិព័រណ៍សាកលវិទ្យាល័យឆ្នាំ2017ថា ការសិក្សានៅថ្នាក់មហាវិទ្យាល័យត្រូវការឱ្យនិស្សិតមានគំនិតច្បាស់លាស់ មានឯកសារយោង និងការសិក្សាស្រាវជ្រាវជាក់លាក់លើអ្វីដែលខ្លួនបានសរសេរ ឬបានសម្រេចឱ្យខ្លាំងឡើង។

ឯកឧត្តម មានប្រសាសន៍ថា៖ "យុវជនខ្មែរដែលត្រៀមខ្លួនចូលមហាវិទ្យាល័យ ត្រូវតែអភិវឌ្ឍខ្លួនឱ្យក្លាយជាមនុស្សដែលចេះគិតពិចារណា គឺពិចារណាលើការវិភាគ វិភាគលើការពិចារណា និងវិភាគលើការវិភាគ"។

ឯកឧត្តម បានលើកឡើងថា ការដែលសិស្សនិស្សិតចូលដល់ថ្នាក់មហាវិទ្យាល័យ គុណភាពរបស់ពួកគេមិនគ្រាន់តែកើនឡើងខ្លាំង តែមុននឹងសម្រេចចិត្តជ្រើសរើសជំនាញណាមួយ សិស្សក៏ត្រូវតែសិក្សា និងពិចារណាឱ្យបានច្បាស់ផងដែរពីចំណាប់ចំណូលចិត្ត បរិស្ថាន និងទេពកោសល្យពីកំណើតរបស់ខ្លួន ដើម្បីធានាថាយើងអាចសិក្សាលើជំនាញដែលត្រឹមត្រូវសម្រាប់ជីវិត។

ការជ្រើសរើសជំនាញ ទាមទារឱ្យមានការប្រឹក្សា ការយកចិត្តទុកដាក់ និងការផ្ដោតសំខាន់លើភាពជាក់ស្ដែងនៃអាជីពការងារដែលនឹងធ្វើនៅថ្ងៃអនាគត ដើម្បីត្រៀមខ្លួនក្លាយជាធនធានមនុស្សដែលមានតម្លៃសម្រាប់សង្គម និងចូលរួមចំណែកយ៉ាងសកម្មជាពលរដ្ឋល្អនៅគ្រប់វិស័យក្នុងសង្គម។

# ហេតុអ្វីកូនក្មេងត្រូវអានសៀវភៅ...



តពីទំព័រ 15 ... ឬចូលចិត្តអាន ពួកគេនឹងអាចទទួលបាននូវប្រយោជន៍ជាច្រើនពីគន្លងអប់រំនៃមេរៀនទាំងអស់នោះ។

កញ្ញា ហ៊ុង ស្រីរត្ន អ្នកនិពន្ធសៀវភៅកុមារសម្រាប់គ្រឹះស្ថានបោះពុម្ពផ្សាយមួយចំនួននៅកម្ពុជា បានប្រាប់ថា កុមារមានគំនិតប្លែកខុសពីមនុស្សធំ ហើយការលេងខ្លះការដោះស្រាយបញ្ហារបស់កុមារអាចធ្វើឱ្យមនុស្សធំមានការភ្ញាក់ផ្អើលផងដែរ។ ការតែងនិពន្ធសៀវភៅរឿងសម្រាប់កុមារគឺត្រូវតែមានវិធីមានដំណោះស្រាយបញ្ហាដែលត្រូវបានបង្កើតឡើងដោយអ្នកនិពន្ធ តែពេលខ្លះអ្នកនិពន្ធមិនអាចឆ្លើយបានល្អបំផុតនោះទេសម្រាប់ការបញ្ចប់រឿងរបស់ខ្លួន។ ហេតុនេះអ្នកនិពន្ធត្រូវទុកឱកាសឱ្យកុមារជំនុំគិតដើម្បីស្វែងរកចម្លើយ ហើយជ្រើសរើសយកគំនិតដែលប្លែក ឬល្អបំផុតដែលខ្លួននឹកស្មានមិនដល់ដើម្បីអប់រំដល់កុមារជាច្រើនទៀតដែលបានអាន។

កញ្ញា ស្រីរត្ន បាននិយាយថា "អ្វីដែលកុមារទទួលយកនូវការអាន និងបទពិសោធន៍ដោះស្រាយបញ្ហាបានល្អគួរតែរួមផ្សំនឹងលក្ខណៈភាពទាំងអស់នោះទៅអនុវត្តក្នុងការរស់នៅរបស់គេ ដែលធ្វើឱ្យពួកគេចេះដោះស្រាយបញ្ហាបានល្អបំផុត ឬជ្រើសរើសគំនិតទាំងអស់នេះជាមូលដ្ឋានដើម្បីបង្កើតដំណោះស្រាយថ្មីប្រកបដោយភាពច្នៃប្រឌិត ដែលគ្រប់គ្នានឹកស្មានមិនដល់"។

បើតាមអ្នកនិពន្ធវ័យក្មេងខាងលើ ការបណ្តុះគំនិតច្នៃប្រឌិត និងភាពឆ្លាតរបស់កុមារ គឺជាការកសាងគ្រឹះមួយយ៉ាងរឹងមាំ សម្រាប់អនាគតរបស់យុវជននៅក្នុងសង្គម។

ស្របគ្នានេះដែរ លោក ឈុំ ជំនិត អ្នកនិពន្ធសៀវភៅកុមារបានលើកឡើងថា សៀវភៅគឺជាស្ពានសម្រាប់កុមារមានគុណតម្លៃខ្ពស់ដើម្បីបណ្តុះផ្តល់គំនិត និងចរិតលក្ខណៈឱ្យកុមារចេះយល់ដឹងដោយខ្លួនឯងនូវអ្វីៗទាំងឡាយណាដែលគួរធ្វើ និងមិនធ្វើទាំងឡាយណាដែលមិនគួរធ្វើ។ ជាពិសេសកុមារដែលចូលចិត្តអានសៀវភៅ គឺជាកុមារឆ្លាតមាន និងមានភាពវៃឆ្លាតជាងកុមារដែលមិនចូលចិត្តអាន។ គំនិតរបស់កុមារដែលធ្លាប់បានអានមានលក្ខណៈទូលំទូលាយ និងមានបន្ទាត់ល្អជាងកុមារដែលមិនចូលចិត្តអានសៀវភៅ។

# Honda Dream 125 ស៊េរី...



តពីទំព័រ 15 ...បញ្ចាំងពីភាពជោគជ័យ គុណតម្លៃ ភាពទាន់សម័យ កិត្យានុភាព និងថាមពល។

ម៉ូតូ ហុងដា ឌ្រីម 125 ស៊េរីថ្មី ត្រូវបានរចនាឡើងតាមបែបថែរក្សាកើត និងប្រណីតភាពដ៏ល្អឯកជាមួយនឹង៖

1- Masterpiece Honda Dream Emblem ដោយ Black Crystal មានក្បូរក្បាច់ល្អគ្មានគូប្រៀប មានភាពល្អឆើត ស័ក្តិសមនឹងអ្នកដែលប្រកបដោយភាពជោគជ័យ

2- New Honda Golden Emblem ស្លាកថ្មី រចនាម៉ូដទំនើបដោយពណ៌មាស ផ្តល់ភាពស្រស់ស្អាតធ្វើឱ្យកាន់តែមានភាពទាក់ទាញ

3- New Golden 3 D Sticker Style ស្ទីគ័រថ្មី ស្រស់ល្អឆើត រចនាឡើងជាមួយពណ៌មាសប្រភេទក្រាហ្វិក 3D ផ្តល់នូវភាពស្រស់ស្អាត ឆើតឆាយយ៉ាងល្អឥតខ្ចោះបង្ហាញពីគុណតម្លៃ និងភាពរឹងមាំពិត

4- New Gorgeous Golden Speedometer កុងទ័រថ្មី បង្ហាញនូវមុខងារដ៏មហាបានយ៉ាងច្បាស់

5- New Deluxe Tail Light ចង្កៀងភ្លើងក្រោយ ឆើតឆាយ ជាមួយនឹងការរចនាម៉ូដយ៉ាងស្រស់ស្អាត

6- New Muffler Design បន្ទះការពារបំពង់ស៊ីម៉ាំង ដែលត្រូវបានរចនាម៉ូដជាមួយនឹងក្រាហ្វិកទំនើបថ្មីស្រស់ស្អាត

7- Crystal Head Light and Real Light with Diamond Shape ចង្កៀងភ្លើងមុខដែលមានរាងដូចពេជ្រ មានភាពរលោងភ្លឺ ព្រមទាំង Inner Line ភ្លើងផ្ទុចក្រីស្តាល់ បង្ហាញនូវភាពភ្លឺច្បាស់។

មានពណ៌បីជម្រើសដូចជា ពណ៌ខ្មៅ ពណ៌ក្រហម និងពណ៌ទឹកប្រាក់ដែលជាពណ៌ពិសេសនៅក្នុងឆ្នាំនេះដោយចំនួនមានកំណត់។ លោកអ្នកអាចរកទិញបាននៅតាមបណ្តាភ្នាក់ងារចែកចាយរបស់ក្រុមហ៊ុន ហុងដា ទូទាំងប្រទេសកម្ពុជា ចាប់ពីថ្ងៃទី28 តុលា ឆ្នាំ2017។

ក្រុមហ៊ុន N.C.X. Company Limited សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភ្នាក់ងារចែកចាយ ហុងដា ដៃគូសហការ និងអតិថិជនទាំងអស់ដែលតែងតែស្រឡាញ់ គាំទ្រ និងជឿជាក់លើម៉ូតូម៉ាក ហុងដាទាំងអស់។



# Electrolux បោះជំហានកាន់តែ...






ភ្នំពេញ (ប្រទ)... ខ្លាំងឆ្នាំនេះដែរតាមរយៈការចាប់ដៃគូសហការជាមួយ ឌេហ៊ីរ គ្រុប ដែលជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណក្នុងការចែកចាយសម្ភារអគ្គិសនី និងគ្រឿងអេឡិចត្រូនិកសម្រាប់ផ្ទះបាយ ដ៏ធំបំផុតក្នុងរាជធានីភ្នំពេញ។

អ្នកចាត់ការទូទៅផ្នែកទីផ្សារអន្តរជាតិផ្នែកសម្ភារអគ្គិសនី និងគ្រឿងអេឡិចត្រូនិកប្រចាំតំបន់អាស៊ីបូព៌ារបស់ក្រុមហ៊ុន Electrolux លោក Rattanaj Manaswatcharapong បានមានប្រសាសន៍ថា សម្រាប់ព្រឹត្តិការណ៍នៃការបើកសម្ពោធផលិតផល Electrolux នៅកម្ពុជានេះ គឺជាព្រឹត្តិការណ៍ដ៏អស្ចារ្យបំផុតដែលក្រុមហ៊ុនបានក្លាយជាដៃគូសហការជាមួយក្រុមហ៊ុន ឌេហ៊ីរ គ្រុប។ តាមរយៈកិច្ចសហការនេះអតិថិជននឹងទទួលបានបទពិសោធន៍នៃការច្នៃប្រឌិតផលិតផល Electrolux។ អ្វីដែលពិសេសនោះគឺគ្រប់ផលិតផលរបស់ Electrolux គឺត្រូវបានផលិតឡើងជាមួយនឹងបច្ចេកវិទ្យាដ៏ទំនើបបំផុតដើម្បីបំពេញតាមសេចក្តីត្រូវការសម្ភារអគ្គិសនី និងគ្រឿងអេឡិចត្រូនិកសម្រាប់ផ្ទះបាយ និងផលិតផលថែរក្សាសម្លៀកបំពាក់ក្នុងប្រទេសកម្ពុជាដែលកំពុងតែមានការរីកចម្រើន និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស។

ក្រុមហ៊ុន Electrolux នឹងផ្តល់ជូនអតិថិជននូវផលិតផលសំខាន់ៗចំនួន3ប្រភេទរួមមាន ទី1 ការផ្តល់ជូនផលិតផលសម្ភារអគ្គិសនី និងគ្រឿងអេឡិចត្រូនិកសម្រាប់ផ្ទះបាយ ទី2 ការថែរក្សាសម្លៀកបំពាក់ជាមួយនឹងម៉ាស៊ីនបោកសម្លៀកបំពាក់ដែលត្រូវបានផលិតឡើងជាមួយនឹងបច្ចេកវិទ្យាទំនើប និងទី3 ការផ្តល់ជូនផាសុខភាព (ផលិតផលបន្សុទ្ធខ្យល់ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបូមធូលី និងម៉ាស៊ីនទឹកក្តៅ ជាដើម)។

បច្ចុប្បន្ន Electrolux គឺជាក្រុមហ៊ុនឈានមុខគេផ្នែកសម្ភារអគ្គិសនី និងគ្រឿងអេឡិចត្រូនិកសម្រាប់គេហដ្ឋានដោយផ្អែកលើការយល់ឃើញ និងសេចក្តីត្រូវការរបស់អតិថិជន។ ផលិតផលរបស់ Electrolux មានដូចជា ទូទឹកកក ចង្ក្រានដុត ចង្ក្រានហ្គាស ចង្ក្រានអគ្គិសនី ម៉ាស៊ីនលាងចាន ម៉ាស៊ីនបោកសម្លៀកបំពាក់ ម៉ាស៊ីនបូមធូលី ម៉ាស៊ីនត្រជាក់ និងសម្ភារអគ្គិសនីអេឡិចត្រូនិកសម្រាប់គេហដ្ឋានជាច្រើនទៀត។

គិតពីឆ្នាំ2016 ក្រុមហ៊ុន Electrolux បានធ្វើការលក់ផលិតផលរបស់ខ្លួនបានប្រាក់ជាង14.51 កោដិដុល្លារអាមេរិក និងមានបុគ្គលិកប្រមាណជាង 55,000នាក់៕

# Samsung បោះទុន18ពាន់លានដុល្លារផលិតឈីបបន្ថែមទៀត



ក្រុមហ៊ុន Samsung Electronics បានប្រកាសថា ខ្លួនកំពុងបោះទុនចំនួន18 ពាន់លានដុល្លារអាមេរិកសម្រាប់ធ្វើការវិនិយោគថ្មីនៅក្នុងការពង្រីកផលិតភាពគ្រឿងឧបករណ៍អេឡិចត្រូនិក នៅក្នុងប្រទេសកូរ៉េខាងត្បូង។

ជាទូទៅអ្នកប្រើប្រាស់ភាគច្រើនសុទ្ធតែធ្លាប់ស្គាល់ម៉ាកសញ្ញារបស់ Samsung តាមរយៈទូរស័ព្ទដៃ និងទូរទស្សន៍ តែតាមការពិតក្រុមហ៊ុន Samsung ក៏ជាក្រុមហ៊ុនធំបំផុតខាងផលិតបន្ទះឈីបអេឡិចត្រូនិចផងដែរ។ តាមរយៈទិន្នន័យចងក្រងដោយ Bloomberg គ្រឿងបង្គុំឧបករណ៍អេឡិចត្រូនិកបង្កើនប្រាក់ចំណូលជាងពាក់កណ្តាលសម្រាប់ក្រុមហ៊ុន Samsung នៅក្នុងឆ្នាំ2016។ ដូច្នេះការវិនិយោគចុងក្រោយនេះ មានន័យថា ប្រាក់ចំណូលទាំងនោះនឹងត្រូវពង្រីកបន្ថែមទៀត។

តាមរយៈការប្រកាសដែលធ្វើឡើងកាលពីថ្ងៃអង្គារ ក្រុមហ៊ុន Samsung បានឱ្យដឹងថាខ្លួននឹងវិនិយោគសង់រោងចក្រ Pyeongtaek ថ្មីនៅត្រឹមឆ្នាំ2021 ដែលមានតម្លៃប្រមាណ13.5ពាន់លានដុល្លារ ហើយគ្រោងនឹងដំឡើងរហូតដល់26ពាន់លានដុល្លារ។ ការប្រកាសវិនិយោគរបស់ក្រុមហ៊ុន Samsung ត្រូវបានធ្វើឡើងស្របពេលដែលការចាប់ផ្តើមផលិតប្រង់ប្រាយដ៏ធំបន្ទះឈីបនៅក្នុងរោងចក្រ Pyeongtaek។

ជាមួយគ្នានេះក្រុមហ៊ុន Samsung ក៏មានគម្រោងក្នុងការបង្កើតរោងចក្រទី2 នៅក្នុងខេត្តស៊ុយអាន ប្រទេសចិន ដែលទីតាំងនោះកំពុងស្ថិតក្នុងការពិចារណា។ រោងចក្រទី1 របស់ Samsung ស្ថិតនៅក្នុងខេត្តស៊ុយអាន ត្រូវបានសាងសង់តាំងពីឆ្នាំ2014 ហើយបច្ចុប្បន្នកំពុងដំណើរការយ៉ាងពេញទំហឹង។ ជាមួយនឹងវិនិយោគថ្មីនេះ Samsung មានបំណងពង្រឹងបណ្តាញរោងចក្រសកលលោក ក៏ដូចជាអភិវឌ្ឍវិស័យបច្ចេកវិទ្យាព័ត៌មានទាំងមូលឱ្យបានឆាប់រហ័សបំផុត៕




ចាប់ពីថ្ងៃ 14 កញ្ញា ដល់ 12 វិច្ឆិកា 2017
ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ម.ក
AEON SPECIALIZED BANK (CAMBODIA) PLC.
023 988 555
www.aeon.com.kh
Model: iPhone8
Color: White
Price Around : $769
Accessories: Charger + Headphone
Duration 12 months
$75/month
Model: iPhone 8 Plus
Color: Gold
Price Around : $879
Accessories: Charger + Headphone
Duration 12 months
$86/month
Model: iPhone 7 Plus 128G |New|
Color: Red
Price Around : $855
Accessories: Charger + Headphone
Duration 12 months
$84/month
Model: iPhone 7 128G |New|
Color: Red
Price Around : $770
Accessories: Charger + Headphone
Duration 12 months
$75/month
Model: Galaxy S8 Plus |New|
Color: Orchid Gray
Price Around: $819
Accessories: Charger + Headphone
Duration 12 months
$80/month
Model: Galaxy S8 |New|
Color: Black
Price Around : $739
Accessories: Charger + Headphone
Duration 12 months
$72/month
Model: iPhone 7 Plus |New|
Color: Gold
Price Around : $680
Accessories: Charger + Headphone
Duration 12 months
$66/month
Model: iPhone 7 |New|
Color: Gold
Price Around : $596
Accessories: Charger + Headphone
Duration 12 months
$58/month
Model: Huawei P10 |New|
Color: Green
Price Around: $610
Accessories: Charger + Headphone
Duration 12 months
$59/month
Model: Huawei Mate 9 Pro|New|
Color: Gold
Price Around: $755
Accessories: Charger + Headphone
Duration 12 months
$74/month
Model: iPad mini4 16G |New|
Color: Gold |Sim|
Price Around : $445
Accessories: Charger
Duration 12 months
$43/month
Model: iPad Air2, 16G |New|
Color: Gold
Price Around : $445
Accessories: Charger
Duration 12 months
$43/month
Model: Huawei P9 Lite |New|
Color: Gold,
Price Around: $229
Accessories: Charger + Headphone
Duration 12 months
$22/month
Model: Galaxy A3 2017 |New|
Color: Rose Gold
Price Around : $285
Accessories: Charger+Headphone
Duration 12 months
$28/month
Model: Galaxy C5 32G |New|
Color: Rose Gold,
Price Around : $295
Accessories: Charger+Headphone
Duration 12 months
$29/month
Model: Galaxy A5 2017 |New|
Color: Gold
Price Around : $395
Accessories: Charger+Hedphone
Duration 12 months
$38/month
Model: Galaxy A7 2017 |New|
Color: Peach Cloud
Price Around: $450
Accessories: Charger + Headphone
Duration 12 months
$44/month
Model: Galaxy C7 32G |New|
Color: Rose Gold
Price Around : $355
Accessories: Charger + Headphone
Duration 12 months
$34/month
ព័ត៌មានបន្ថែម
សម្រាប់សេវាកម្មបង់រំលស់
AEON
023 988 555
www.aeon.com.kh
www.facebook.com/aeonbank.kh

AXIS
RESIDENCES
金轴丽苑

Axis Residences is the First Condominium in Cambodia achieving "Green Mark Gold" standard by Building Construction Authority of Singapore.




សូមមកទទួលយកការរស់នៅបែបទំនើបនិងទាន់សម័យនៅថ្ងៃនេះ ជាមួយនឹង៖

- ខុនដូដែលសាងសង់ឡើងតាមបទដ្ឋានបច្ចេកទេសរបស់ប្រទេសសិង្ហបុរី
- មានអាងហែលទឹកដែលមានប្រវែងស្តង់ដារ អូឡាំពិក (៥០ម៉ែត្រ) សង់នៅផ្ទាល់ដី
- ការផ្តល់ជូនឥតគិតថ្លៃ នូវទីកន្លែងសំរាប់ ការលេងកំសាន្ត, ការហាត់ប្រាណ, ទីលានវាយតេន្នីសខ្នាតអន្តរជាតិ។ល។

SPRING
CJW DEVELOPMENT PTE LTD
诚信发展有限公司

PhillipBank
Your Partner In Finance

SLEUKRITH
realty

Marketing & Sales Agency
070 636 805
010 988 888

KAMPU SUN
カンプサン株式会社

# ឱកាសទៅហ្វឹកហ្វឺនការងារនៅប្រទេសជប៉ុន

ក្រុមហ៊ុន **KAMPUSUN MANPOWER LTD** យើងខ្ញុំ ត្រូវការជ្រើសរើសសិក្ខាកាមទៅបណ្តុះបណ្តាលការងារ នៅប្រទេសជប៉ុនដែលអាចទទួលបានប្រាក់ខែចាប់ពី 1,200ដុល្លារ - 1,800ដុល្លារ ក្នុង1ខែ និងទទួលបានលិខិតបញ្ជាក់ការសិក្សាពីប្រទេសជប៉ុន

**ផ្នែកដែលជ្រើសរើសមានដូចខាងក្រោម**




1 ផ្នែកកសិកម្ម 2 ផ្នែកសំណង់ 3 ផ្នែកវេចខ្ចប់ 4 ផ្នែកនេសាទ និងប្រភេទការងារផ្សេងៗទៀត...

**លក្ខខណ្ឌនៃការជ្រើសរើស**
- មានអាយុចាប់ពី 19ឆ្នាំ ដល់ 35ឆ្នាំ
- មានសុខភាពល្អ និងកាយសម្បទាមាំមួន
- គ្មានស្លាកស្នាមសាក់
- មានការយល់ព្រមពីក្រុមគ្រួសារ

**លក្ខខណ្ឌនៃការចុះឈ្មោះ**
- រូបថត 4x6 ចំនួន 8សន្លឹក
- អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងសំបុត្រកំណើត

បញ្ជាក់ : ការចុះឈ្មោះមិនចំណាយប្រាក់ទេ

អាសយដ្ឋានៈ ផ្ទះលេខ 15B ផ្លូវលេខ 502
សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ភ្នំពេញ12307
**070 669 030 / 012 669 030**
**012 610 111 / 098 669 030**




ឡារ៉ែន
LA REINE

# ដំណឹងជ្រើសរើសបុគ្គលិក

ហាង ឡារ៉ែន លក់សម្លៀកបំពាក់ ត្រូវការជ្រើសរើសបុគ្គលិក
ភេទស្រី ចំនួន១រូប ជាបន្ទាន់
ក្នុងមុខតំណែងជា ជាងកាត់ដេរសម្លៀកបំពាក់។



**តម្រូវការ**
- មានអាយុចាប់ពី 20-30ឆ្នាំ
- ចេះកាត់ និងដេរសម្លៀកបំពាក់
- ចេះសេរ៉េ ខោអាវ
- រួសរាយរាក់ទាក់ជាមួយភ្ញៀវ និងក្រុមការងារ

**ផុតកំណត់**
**ថ្ងៃទី14 ខែវិច្ឆិកា ឆ្នាំ2017**

បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមទំនាក់ទំនងតាមអាសយដ្ឋាន
អគារលេខ57 មហាវិថីព្រះសីហនុ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
ឬតាមរយៈលេខទូរស័ព្ទ : 081 678 111
អ៊ីមែល : info@lareine.com.kh - cc: naren@lareine.com.kh

វគ្គសិក្សាខ្លី
# AML Soft Skills
រៀនគិត និងរៀនអំពីមនុស្ស

We Always Care
About Your Future



## 7 Steps for Your Future Success

*7. Create Living Values*
*6. Public Speaking Skill*
*5. Passion to Your Success*
*4. How to Achieve Your Goal*
*3. Remove Your Fear, Build Your confidence*
*2. Productive Mental Attitude*
*1. Building Self-Motivation*

រៀនរយៈពេល ៣ខែរៀនតែថ្ងៃអាទិត្យ
តម្លៃសិក្សា ២៤៥ដុល្លារ/នាក់
ទទួលចុះឈ្មោះរៀងរាល់ថ្ងៃ



សូមទាក់ទង
កញ្ញា ឡេង អាលីយ៉ា
អ្នកសម្របសម្រួលវគ្គ AML Soft Skills
**010 910 777**
**078 910 777**
**016 500 990**

We're HIRING

LA REINE MEDIA

# REPORTER

La Reine Media is a premium advertising media (newspaper, magazine and website) in Cambodia. we are seeking 1 person.

**Responsibilities**
- Attend relevant events, fairs and conferences.
- Ability to pick good quote from famous and success people.
- Create and maintain a network of contacts.
- Conduct face-to-face or phone interview with related individual concerning some interested events.
- Hunt up for up-to-date news.

**Requirements**
- At least one year experience in related filed.
- Know how to take a photo and video is an advantage
- Being enthusiastic in writing.
- Good command in English, Microsoft Office, Email and Internet.
- Good communication skill.
- Creative, hard-working attitude and team player.
- Have your own transportation.

**Salary : Negotiable**
**Closing Date: 14 November 2017**

Interested applicants can submit C.V with cover letter to
Address: #57, Sihanouk Blvd., Sangkat Chaktomuk,
Khan Daun Penh, Phnom Penh

**Email : info@lareine.com.kh**
**sophoan@lareine.com.kh**
**H/P : 023 215 717**
**078 610 111**




Carabao ENERGY DRINK
ខារ៉ាបាវ 50 លានរៀល ចែករង្វាន់ពិតៗ!
ខារ៉ាបាវ ជួយកែប្រែជីវិតលោកអ្នក
ក្លាយជាអ្នកមានភ្លាមៗ
ឈ្មោះ គុច ខេមរា
មុខរបរ ជាបុគ្គលិកប្រើការងារនៅ ក្រុង បាវិត
តើសេដ្ឋីបន្ទាប់ជាអ្នកណា ?
រង្វាន់នៅមានច្រើនទៀត អ្នកក៏អាចក្លាយជាអ្នកមាន
សូមបញ្ជាក់ រង្វាន់ 50លានរៀល នៅសល់ 39រង្វាន់ ម៉ូតូនៅសល់ 40រង្វាន់ iphone7 នៅសល់ 40រង្វាន់ទៀតកំពុងរង់ចាំអ្នក ដោយលោកអ្នកគ្រាន់តែពិសារភេសជ្ជៈ ខារ៉ាបាវ ហើយពិនិត្យមើលក្រវិលកំប៉ុង លោកអ្នកនឹងមានភ្លាមៗ!
ខារ៉ាបាវ អ្នកគតស៊ូដ៏អស្ចារ្យ